# វិមជ្ឈការ និងវិសហមជ្ឈការនៅតំបន់ អាស៊ីអាគ្នេយ៍ ៖ មេរៀនបទពិសោធន៍




សាស្ត្រាចារ្យបណ្ឌិត ប៉ាទ្រីក ហ្សីគិនហោន
សាស្ត្រាចារ្យនៃវិទ្យាស្ថានអាស៊ី អឺរ៉ុប
នៃមហាវិទ្យាល័យម៉ាឡេស៊ី
កូឡាឡាំពួរ

1

## ហេតុអ្វីចាំបាច់ត្រូវធ្វើវិមជ្ឈការ?

- ដើម្បីលើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងដើម្បីបំពេញបំណងប្រាថ្នារបស់ប្រជាពលរដ្ឋទូទៅជាមួយនឹងប្រព័ន្ធនយោបាយ
- ដើម្បីកាត់បន្ថយភាពតានតឹងជាមួយនឹងក្រុមជនជាតិ/សាសនាភាគតិច ឬចលនាផ្ដាច់ខ្លួន
- អាចជួយធានាឱ្យកាន់តែមានសមធម៌ក្នុងការបែងចែកធនធាន

ផលប្រយោជន៍សំខាន់ៗ៖

- បង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន
- ជម្រុញឱ្យមានគំនិតផ្ដួចផ្ដើមនិងការច្នៃប្រឌិត
- ពង្រឹងគណនេយ្យភាព និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ

2

## ប្រភេទផ្សេងៗនៃវិមជ្ឈការក្នុងតំបន់ អាស៊ីអាគ្នេយ៍




**មិនមានការអនុវត្ត**
- សាំងហ្គាពួរ និងព្រុយនេ

**ការប្រគល់**
- ឥណ្ឌូនេស៊ី

**ប្រតិភូកម្ម**
- ម៉ាឡេស៊ី ហ្វីលីពីន កម្ពុជា

**វិសហមជ្ឈការ**
- ថៃ កម្ពុជា ឡាវ វៀតណាម ភូមា

3

## មេរៀនបទពិសោធន៍ពីវិមជ្ឈការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍

- ផ្អែកតាមការសម្ភាសន៍ជាមួយរដ្ឋមន្ត្រី សមាជិកសភា សមាជិកគណៈកម្មាធិការផែនការជាតិ អ្នកស្រាវជ្រាវ និងអ្នកជំនាញការផ្នែកអភិវឌ្ឍន៍នៅក្នុងប្រទេសឥណ្ឌូនេស៊ី ប្រទេសថៃ និងប្រទេសហ្វីលីពីន
- ភាពមិនទុកចិត្តជាទូទៅរបស់រជនថ្នាក់ជាតិចំពោះរដ្ឋបាលមូលដ្ឋាន (មិនមានជំនាញ ខ្វះការអប់រំ គំនិតខ្លី ពុករលួយ និងមិនទាន់ត្រៀមខ្លួនរួចរាល់)
- **ករណីលើកលែង៖** អំឡុងពេលនៃការផ្លាស់ប្តូរផ្នែកនយោបាយ (ប្រទេសឥណ្ឌូនេស៊ី ក្នុងឆ្នាំ១៩៩៨ ប្រទេសហ្វីលីពីន ក្នុងឆ្នាំ១៩៨៦)

4

## វិមជ្ឈការនៅក្នុងប្រទេសឥណ្ឌូ ស៊ី



- វិមជ្ឈការជាគំហុក "Big Bang" ដែលចាប់ផ្តើមនៅឆ្នាំ១៩៩៩
- ការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈភាគច្រើនត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលមូលដ្ឋាន
- មន្ត្រីសាធារណៈចំនួន២/៣ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលមូលដ្ឋាន
- ថ្នាក់ដឹកនាំមូលដ្ឋានត្រូវបានបោះឆ្នោតជ្រើសរើសផ្ទាល់ដោយប្រជាពលរដ្ឋ
- រដ្ឋបាលមូលដ្ឋានចំណាយជាង៤០%នៃចំណាយទាំងអស់របស់រដ្ឋាភិបាល ហើយរដ្ឋបាលមូលដ្ឋានមានចំណូលផ្ទាល់របស់ខ្លួន

5

## វិមជ្ឈការនៅក្នុងប្រទេសថៃ និងប្រទេសហ្វីលីពីន

ប្រទេសហ្វីលីពីន



- ច្បាប់ស្តីពីរដ្ឋបាលមូលដ្ឋានឆ្នាំ១៩៩១
- ការបង្កើតឱ្យមានរដ្ឋបាលមូលដ្ឋានចំនួនរាប់រយ
- ស្វ័យភាពផ្នែកនយោបាយ និងប្រភពចំណូល(ពន្ធ)នៅមានកំណត់
- កំពុងជជែកវែកញែកអំពីការកែប្រែរដ្ឋធម្មនុញ្ញដើម្បីផ្លាស់ប្តូរទៅជារដ្ឋសហព័ន្ធមួយ



ប្រទេសថៃ

- វិមជ្ឈការត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៧ និង២០០៧
- លិខិតបទដ្ឋាននៅមិនទាន់មានភាពច្បាស់លាស់
- សហគមន៍មានស្វ័យភាពតិចតួច(ផ្នែកហិរញ្ញវត្ថុ)
- រដ្ឋាភិបាលបច្ចុប្បន្នពុំបានអនុវត្តវិមជ្ឈការឱ្យបានស៊ីជម្រៅ

6

## វិមជ្ឈការហិរញ្ញវត្ថុ: បទពិសោធន៍នៅឥណ្ឌូនេស៊ី/ហ្វីលីពីន

- **បញ្ហា៖** អតុល្យភាពផ្នែកហិរញ្ញវត្ថុរវាងរដ្ឋបាលមូលដ្ឋានក្រីក្រ និងរដ្ឋបាលមានធនធានច្រើន
- **ដំណោះស្រាយ៖** វិធានការរបស់ថ្នាក់ជាតិដើម្បីធានាដល់សុខដុមនីយកម្ម និងការបង្កើនសិទ្ធអំណាចរបស់រដ្ឋបាលខេត្តក្នុងការត្រួតពិនិត្យមើលពីលើ
- យ៉ាងណាមិញ: គំលាតនៅតែកាន់តែ ធំ




7

## វិមជ្ឈការផ្នែករដ្ឋបាល: បទពិសោធន៍នៅឥណ្ឌូនេស៊ី/ហ្វីលីពីន

- **បញ្ហា៖** មានភាពខុសគ្នាយ៉ាងខ្លាំងក្នុងក្របខណ្ឌនៃការផ្តល់សេវាសាធារណៈនានា(សុខាភិបាល អប់រំ) រវាងតំបន់នានា
- **ដំណោះស្រាយ៖** ការដាក់ចេញនៅស្តង់ដាអប្បបរិមានៃសេវាសម្រាប់រដ្ឋបាលមូលដ្ឋាន
- ការបង្កើតជាកញ្ចប់ធនធានពិសេសសម្រាប់ជួយគាំទ្រដល់រដ្ឋបាលមូលដ្ឋានក្រីក្រ




8

## វិមជ្ឈការផ្នែករដ្ឋបាល: បទពិសោធន៍នៅឥណ្ឌូនេស៊ី/ហ្វីលីពីន

- **បញ្ហា៖** ថ្នាក់ដឹកនាំរដ្ឋបាលមូលដ្ឋានប្រើប្រាស់បែបផែនគ្រប់គ្រងជាថៅហ្វាយនាយ និងតែងតាំង សាច់ញាតិ មិត្តភ័ក្រ្ត និងអ្នកគាំទ្ររបស់ខ្លួន ដែលមិនមែនជាអ្នកដែលមានសមត្ថភាពជាងគេនៅមូលដ្ឋាន
- **បញ្ហា៖** ថ្នាក់ដឹកនាំរដ្ឋបាលមូលដ្ឋានដាក់ចេញនូវលិខិតបទដ្ឋានដោយមានការរើសអើងចំពោះក្រុមភាគតិច
- **ដំណោះស្រាយ៖** តុលាការធម្មនុញ្ញជាតិបានប្រកាសអសុពលភាពនៃលិខិតបទដ្ឋានមួយចំនួនរបស់រដ្ឋបាលមូលដ្ឋាន

9

## វិមជ្ឈការផ្នែករដ្ឋបាល:
## បទពិសោធន៍ពីប្រទេសឥណ្ឌូនេស៊ី

- **បញ្ហា៖** ក្រសួងស្ថាប័នមួយចំនួនមានការលំបាកខ្លាំងក្នុងការសម្របសម្រួលជាមួយក្រសួងស្ថាប័នផ្សេងៗទៀតរបស់រដ្ឋាភិបាល។
- **ដំណោះស្រាយ៖** រៀបចំកិច្ចប្រជុំសម្របសម្រួលឲ្យបានទៀតទាត់ និងមានការបែងចែកការទទួលខុសត្រូវឱ្យបានច្បាស់លាស់។

10

## វិមជ្ឈការផ្នែករដ្ឋបាល:
## បទពិសោធន៍ពីប្រទេសឥណ្ឌូនេស៊ី

- **បញ្ហា៖** រដ្ឋបាលមូលដ្ឋានមានការលំបាកក្នុងការរាយការណ៍អំពីការប្រើប្រាស់ថវិកា(block grants) ដែលផ្តល់ដោយរដ្ឋាភិបាលកណ្តាល
- **ដំណោះស្រាយ៖** ប្រព័ន្ធរបាយការណ៍អេឡិចត្រូនិក(web-based reporting system)ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០១១មក។ រដ្ឋបាលមូលដ្ឋានបានបញ្ជូនរបាយការណ៍បច្ចេកទេស និងហិរញ្ញវត្ថុរបស់ខ្លួនតាមប្រព័ន្ធរបាយការណ៍អេឡិចត្រូនិក (ដែលមានតម្លាភាព និងមានភាពងាយស្រួលក្នុងការរាយការណ៍ និងការតាមដានត្រួតពិនិត្យ។



## វិមជ្ឈការរដ្ឋបាល:
## បទពិសោធន៍ពីប្រទេសឥណ្ឌូនេស៊ី

- ការិយាធិបតេយ្យនៅមូលដ្ឋានដែលនាំឲ្យការងារគ្មានប្រសិទ្ធភាព
- **ដំណោះស្រាយ៖** ដាក់ឲ្យអនុវត្តនូវការិយាល័យច្រកចេញចូលតែមួយ (One Stop Counters) នៅរដ្ឋបាលមូលដ្ឋាន – និងវិធានការអភិវឌ្ឍន៍សមត្ថភាពដល់មន្ត្រីសាធារណៈរបស់រដ្ឋបាលមូលដ្ឋាន។




12

## អនុសាសន៍នានាសម្រាប់ភាពជោគជ័យនៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ

- រដ្ឋបាលមូលដ្ឋានត្រូវការចាំបាច់នូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីអនុវត្តមុខងារ និងដើម្បីផ្តល់សេវាសាធារណៈឲ្យបានសមស្របនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ក្រសួងស្ថាប័នដែលមានតួនាទីក្នុងការសម្របសម្រួលកិច្ចដំណើរការវិមជ្ឈការត្រូវសហការឲ្យបានជិតស្និតជាមួយក្រសួងហិរញ្ញវត្ថុដើម្បីធានាថាធនធាននានាត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបានគ្រប់គ្រាន់។
- ក្រសួងស្ថាប័នវិស័យនានាត្រូវធានាថាដល់ការជ្រើសរើសនៅមុខងារដែលមានលក្ខណៈសមស្របដើម្បីប្រគល់ឬធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកម្ពស់ការផ្តលសេវាប្រកបដោយគុណភាពខ្ពស់។

13

## អនុសាសន៍នានាសម្រាប់ភាពជោគជ័យនៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ

- ថ្នាក់ជាតិគួរបង្កើនការយកចិត្តទុកដាក់ទៅលើការត្រួតពិនិត្យ តាមដាន និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិនានាផ្តល់សេវាប្រកបដោយគុណភាពខ្ពស់
- ក្រសួងស្ថាប័នថ្នាក់ជាតិ ចាំបាច់ត្រូវមានជំនឿជឿជាក់ទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិលើការអនុវត្តមុខងារនានា និងចាំបាច់ត្រូវមានការលើកលែងដល់ដែលជួនកាលអាចអនុវត្តខុសឆ្គងដែលអាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើជាមេរៀនពិសោធន៍

14

## សេចក្តីសន្និដ្ឋានទូទៅ

- កិច្ចដំណើរការវិមជ្ឈការពុំមែនជាឱសថទិព្វសម្រាប់ការលើកកម្ពស់អភិបាលកិច្ចល្អ និងការអភិវឌ្ឍសេដ្ឋកិច្ចនោះឡើយ
- ទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់សម្រាប់រដ្ឋបាលមូលដ្ឋានដែលត្រូវមានការឆ្លើយតបកាន់តែច្រើនឡើងចំពោះតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងមានការយកចិត្តទុកដាក់កាន់តែច្រើនពិតម្រូវការ និងកង្វល់របស់ប្រជាពលរដ្ឋ
- បទពិសោធន៍នានាពីបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ផ្សេងទៀតគប្បីត្រូវបានយកមកពិចារណា

15

## វិមជ្ឈការ និងវិសហមជ្ឈការនៅតំបន់ អាស៊ីអាគ្នេយ៍ ៖ មេរៀនបទពិសោធន៍




សាស្ត្រាចារ្យបណ្ឌិត ប៉ាទ្រីក ហ្សីគិនហេន
សាស្ត្រាចារ្យនៃវិទ្យាស្ថានអាស៊ី អឺរ៉ុប
នៃមហាវិទ្យាល័យម៉ាឡេស៊ី
កូឡាឡាំពួរ

16